# ការទាយទំនាយ ការបើកសំដែង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងការណែនាំ

Divination, Revelation, God's Will and Guidance

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## របៀបដែលសាសន៍ដទៃទស្សន៍ទាយអំពីបំណងព្រះហឫទ័យរបស់ព្រះនៃពួកគេ

មនុស្សរស់នៅក្នុងវប្បធម៌និងសាសនាផ្សេងៗព្យាយាមស្វែងរកទំនាយ ឬការបើកសំដែងអធិធម្មជាតិដើម្បីធ្វើជាមគ្គុទ្ទេសក៍សំរាប់អនុវត្តតាមក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ មានអត្ថបទចាស់ៗនៅសម័យបុរាណជាច្រើនបានរៀបរាប់អំពីរបៀប ឬមធ្យោបាយក្នុងការបង្រៀនអំពី ការទាយពីវិញ្ញាណ ឬការទាយពីទេវតា ឬគំនិតឬបំណងរបស់ព្រះរបស់ពួកគេជាដើម។ល។ តាមពិតទៅ នេះគឺជារឿងដ៏សាមញ្ញបំផុតមួយ ដែលបានកើតមានឡើងនៅសម័យបុរាណ ហើយវាក៏មានភាពពេញនិយមផងដែរសំរាប់សាសនានៅសម័យទំនើបនេះ។ ទង្វើបែបនេះហាក់ដូចជាអាកប្បកិរិយាតាំងពីសម័យបុរាណមក។ ឧទាហរណ៍ដូចជា នៅក្នុងពិធីចូលឆ្នាំខ្មែរ ប្រជាជនកម្ពុជាប្រឹងស្វែងរក «ការបើកសំដែង» ពីវិញ្ញាណនិងទេវតាតាមរយៈការសែនព្រេនផ្សេងៗ។ នៅពេលបុណ្យចូលឆ្នាំ ប្រជាជនខ្មែរនាំគ្នាសំអាតផ្ទះសំបែង នាំយកផ្លែឈើផ្លែព្រៃសំរាប់ទទួលទេវតាឆ្នាំថ្មីដើម្បីឱ្យបានទទួលសិរីសួស្តី  ភ័ព្វសំណាងនៅក្នុងឱកាសចូលឆ្នាំថ្មីនោះ។ មួយទៀត ចំពោះរឿងអាពាហ៍ពិពាហ៍វិញ ក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយរឿងនេះដែរ គឺមុននឹងរៀបអាពាហ៍ពិពាហ៍ ពួកគេតែងនាំគ្នាទៅរកហោឱ្យគន់គូមើលវេលាដើម្បីឱ្យដឹងថា ពេលណាជាពេលល្អសំរាប់ការប្រារព្ធពិធីមង្គលការរបស់ពួកគេ។ តើមានពិធីណាផ្សេងទៀតទេ ដែលប្រជាពលរដ្ឋខ្មែរធ្វើដើម្បីស្វែងរកការបើកសំដែង និងការដឹកនាំពីព្រះ ឬទេវតាឬវិញ្ញាណផ្សេងៗ?

ឧទាហរណ៍មួយទៀតដែលជាផ្នែកមួយនៃប្រពៃណីរបស់ខ្មែរ គឺពិធីច្រត់ព្រះនង្គ័ល។ គេប្រារព្ធពិធីនេះនៅក្នុងព្រះបរមរាជវាំង។ នៅក្នុងពិធីនេះ គេដាក់ផលធញ្ញជាតិជាច្រើនមុខដូចជា ស្រូវ ពោត សណ្តែកល្ង ជាដើម ហើយគេក៏ដាក់ទឹក និងស្រាផងដែរ។ បន្ទាប់មកគេដឹកគោដែលគេបានរៀបចំជាស្រេចសំរាប់ប្រារព្ធពិធីនោះឱ្យដើរស៊ីគ្រប់ទាំងធញ្ញជាតិទាំងអស់ខាងលើ។ នៅពេលដែលគេធ្វើពិធីនេះហើយ គេអាចទាយដឹងថាឆ្នាំនេះផលស្រូវ សណ្តែក ល្ង។ល។ បានតិច ឬច្រើនតាមរយៈសត្វគោដែលស៊ីផលទាំងនោះ។ បើគោស៊ីផលទាំងនោះច្រើនមានន័យថា ឆ្នាំនេះនឹងកើតផលច្រើន តែបើគោស៊ីផលនោះតិចនោះ មានន័យថា ឆ្នាំនេះនឹងមានទិន្នផលទាបដែរ។

សំរាប់សាសន៍ដទៃវិញ ក៏មានវិធីជាច្រើនដែរដើម្បីទាយពីភ័ព្វវាសនានាពេលអនាគតនិងដើម្បីធ្វើជាមគ្គុទ្ទេសក៍សំរាប់ពួកគេអនុវត្តតាម។ ពិធីរបស់ពួកគេទាំងអស់នោះរួមមានទាំង៖

១. ការចាប់ឆ្នោត នេះគឺជារបៀបមួយនៃការទស្សនទាយរបស់ពួកគេ។ យើងអាចមើលឃើញគេប្រើវិធីនេះនៅក្នុងព្រះគម្ពីរយ៉ូណាស ១:៧។ នៅក្នុងព្រះគម្ពីរយ៉ូណាស ពួកនាវិកចង់បានការបើកសំដែងពិសេសមួយពីអំណាចទេវតា ឬព្រះណាមួយដើម្បីឱ្យដឹងប្រាកដថា តើភាពវឹកវរដែលកំពុងតែកើតមាននៅក្នុងចំណោមពួកគេនេះ កើតឡើងដោយសារអ្នកណា។ របៀបដែលពួកគេប្រើដើម្បីឱ្យដឹងពីអាថ៌កំបាំងនេះគឺ ការចាប់ឆ្នោត។

២. ការសិក្សាថ្លើម នៅក្នុងវប្បធម៌ខ្លះ ពួកសាសន៍ដទៃជឿថា ភាពឆ្លាតវៃ ប្រាជ្ញានិងការចងចាំមាននៅក្នុងថ្លើម មិនមែននៅក្នុងខួរក្បាលនោះទេ ដូច្នេះហើយបានជាពួកគេបង្កើតវគ្គសិក្សាដ៏ធំមួយអំពីថ្លើម។ ថ្លើមជាសរីរាង្គមួយធ្ងន់ជាងគេ ដូច្នេះហើយនៅពេលដែលព្រះចង់បើកសំដែងពីហឫទ័យរបស់ទ្រង់ដល់មនុស្ស នោះទ្រង់នឹងបើកសំដែងតាមរយៈសរីរាង្គដែលធ្ងន់ និងសំខាន់ជាងគេបំផុតនោះ។ ពួកសង្ឃនៅសម័យបុរាណបានយកសត្វចៀមទៅថ្វាយយញ្ញបូជា ហើយដើម្បីឱ្យបានដឹងថា តើព្រះមានបន្ទូលមកពួកគេយ៉ាងម៉េចខ្លះនោះ ពួកគេត្រូវ «ពិនិត្យមើល» ថ្លើម និងពោះវៀនរបស់វា។ ការអនុវត្តបែបនេះមានសារៈសំខាន់បំផុត ជាពិសេសនៅពេលដែលស្រុកកំពុងមានសង្គ្រាម ឬជួបគ្រោះទុរ្ភិក្ស។ ពួកក្រុមសង្ឃអាចសំឡាប់ចៀមរាប់សិបក្បាលដើម្បីសិក្សាពីថ្លើមរបស់វា ដោយសង្ឃឹមថា នឹងអាចរកឃើញទីសំគាល់ប្រហាក់ប្រហែលគ្នានៅលើថ្លើមសត្វទាំងនោះ ដើម្បីឱ្យពួកគេកាន់តែដឹងប្រាកដច្បាស់ថែមទៀតអំពីបំណងព្រះហឫទ័យព្រះរបស់ពួកគេ។

៣. ការប្រើផ្លែព្រួញ យើងអាចរកឃើញឧទាហរណ៍អំពីការប្រើនេះនៅក្នុងព្រះគម្ពីរអេសេគាល ២១:២១។ ការដែលប្រើផ្លែព្រួញដើម្បីទស្សនទាយនេះគឺទាក់ទងនឹងស្តេចមួយអង្គ ដែលពេលនោះទ្រង់មិនដឹងប្រាកដថា តើផ្លូវមួយណាដែលទ្រង់ត្រូវធ្វើដំណើរឆ្លងកាត់។ ដូច្នេះ ដើម្បីឱ្យបានដឹងច្បាស់ និងទទួលបានមគ្គុទ្ទេសក៍អធិធម្មជាតិ នោះស្តេចបានប្រើរបៀបទស្សនទាយបីខុសៗគ្នា។ គេអាចប្រើផ្លែព្រួញនេះក្នុងរបៀបផ្សេងៗពីគ្នា ដើម្បីទទួលការបើកសំដែង និងមគ្គុទ្ទេសក៍ពីព្រះរបស់ពួកគេ។ គេធ្វើពិធីនេះដោយបោះផ្លែព្រួញទៅលើដី ដើម្បីឱ្យដឹងថា តើចុងព្រួញនោះចង្អុលទៅទិសណាមួយ។ ពួកគេជឿលើការគ្រប់គ្រងរបស់ព្រះ (ព្រះរបស់ពួកគេ) គឺនៅពេលដែលចុងព្រួញចង្អុលទៅកន្លែងណា នោះហើយជាការបើកសំដែងអំពីព្រះហឫទ័យរបស់ព្រះសំរាប់ពួកគេ។ យ៉ាងហោចក៏មានឧទាហរណ៍មួយដែរនៅក្នុងប្រវត្តិសាស្ត្រ គឺមាននិយាយពីស្តេចមួយអង្គដែលមានពលទ័ពពូកែក្នុងចំបាំង តែបានដកទ័ពថយ មិនព្រមធ្វើការវាយប្រហារ ដោយព្រោះតែទីសំគាល់នៃផ្លែព្រួញបានប្រាប់ឱ្យទ្រង់ត្រូវដកទ័ពថយ។

៤. រូបព្រះនៅតាមផ្ទះ នេះគឺជាវិធីដែលគេបានប្រើជាទូទៅ ដើម្បីទទួលបានទីសំគាល់ពីព្រះ ឬពីវិញ្ញាណផ្សេងៗ។ ពួកគេនាំគ្នាថ្វាយដង្វាយនិងយញ្ញបូជា សំរាប់ផ្គាប់ដល់ព្រះ ឬវិញ្ញាណទាំងនោះ។ តែព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា រាស្ត្ររបស់ព្រះជាម្ចាស់មិនត្រូវវិលបែរទៅឯរូបព្រះវិញឡើយ (និក្ខមនំ ២០:៤, លេវីវិន័យ ១៩:៤, អេសាយ ៤៤:៩)។ គេតែងតែស្អប់ដល់ពួកអ៊ីស្រាអែល ដែលរស់នៅក្នុងគ្រាសញ្ញាចាស់ និងពួកគ្រីស្ទបរិស័ទសព្វថ្ងៃ ដោយហេតុថា ពួកនេះមិនដើរតាមរូបព្រះ (១ថែស្សាឡូនិច ១:៩)។ ពួកហោរាតែងតែធ្វើការរិះគន់ ខ្លាំងៗទៅលើពួកអ៊ីស្រាអែលនៅពេលដែលពួកនេះស្វែងរកមគ្គុទ្ទេសក៍ពីរូបព្រះ (ហោសេ ៤:១២)។ បញ្ហារបស់ពួកអ៊ីស្រាអែលនៅគ្រាសញ្ញាចាស់កើតឡើងម្តងហើយម្តងទៀត ដោយសារតែពួកគេបដិសេធន៍ព្រះដ៏ពិត ហើយវិលបែរទៅរករូបព្រះ ឬព្រះក្លែងក្លាយវិញ។

៥. តារាសាស្ត្រ មនុស្សម្នាជាច្រើននៅជុំវិញពិភពលោកប្រឹងប្រែងស្វែងរកការដឹកនាំនិងការបើកសំដែងអំពីថ្ងៃអនាគតតាមរយៈការសិក្សាលើហ្វូងតារា។ ជាថ្មីម្តងទៀត ព្រះគម្ពីរបានហាមផ្តាច់ចំពោះការអនុវត្តន៍ទង្វើបែបនេះ (អេសាយ ៤៧:១៣, ២ពង្សាវតាក្សត្រ ២៣:៤-៥, យេរេមា ១០:២-៣)។ គំនិតដើមឬដំបូងបង្អស់ដែលនៅពីក្រោយការសិក្សាលើដួងតារានេះ គឺមនុស្សគិតថា ដួងតារាទាំងឡាយគឺជាវិមានសួគ៌របស់ព្រះមួយអង្គ ឬច្រើនអង្គ។ ដូច្នេះ តារាគឺជាវត្ថុបើកសំដែងពីព្រះហឫទ័យរបស់ទ្រង់។ គេគិតថា ចលនាវិកិលរបស់ភព និងតារាទាំងឡាយធ្វើឱ្យមានហេតុការណ៍កើតឡើងនៅលើផែនដី។

៦. ការប្រើប្រាស់ទឹក យោងតាមប្រវត្តិសាស្ត្រ មនុស្សជាច្រើនបានជឿថា ពួកគេអាចដឹងពីអនាគតរបស់អ្នកដែលប្រើអង្គធាតុរាវណាមួយ ដូចជាទឹកជាដើមនោះ ដោយគ្រាន់តែសង្កេតមើលអង្គធាតុរាវដែលនៅសល់ក្នុងចានឬពែងរបស់អ្នកនោះ។ វិធីទាយទំនាយនេះមាននិយាយនៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ៤៤:៥។ ក្បួនទំនាយនេះមានលំនាំដូចគ្នានឹងការទាយតាមស្លឹកតែ ឬសន្លឹកបៀរដែរ ដោយពួកគេជឿថា «កម្មផល» របស់មនុស្សម្នាក់មានឥទ្ធិពលទៅលើគ្រប់អ្វីដែលគាត់ប៉ះពាល់។

៧. ការនិយាយជាមួយវិញ្ញាណ អ្នកខ្លះចង់ដឹងថា តើនៅថ្ងៃអនាគតនឹងមានអ្វីកើតឡើង (ការបើក សំដែង ការដឹកនាំ និងចំណេះដឹង) ដោយធ្វើការសន្ទនាជាមួយនឹងវិញ្ញាណផ្សេងៗ។ ប៉ុន្តែប្រសិនបើ យើងក្រឡេកមើលសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរវិញ យើងឃើញថា ព្រះគម្ពីរបានហាមដាច់ខាត ហើយនិងជំនុំជំរះផងដែរចំពោះការអនុវត្តន៍នូវទង្វើបែបនេះ (លេវីវិន័យ ១៩:២៦, ៣១, ចោទិយកថា ១៨:១០-១២, ១៤-១៦, អេសាយ ៨:១៩)។

៨. ហោរា បទទំនាយនិងគ្រូគន់គូ យោងតាមប្រវត្តិសាស្ត្រយើងឃើញថា ពួកបណ្តាជនជាញយៗ តែងតែស្តាប់តាមគ្រូគន់គូដើម្បីជួយក្នុងការកាត់ស្រាយទីសំគាល់ពីព្រះ ឬទេវតា ឬវិញ្ញាណណាមួយ។ តាមពិត នៅក្នុងព្រះគម្ពីរមានហោរាជាច្រើនដែលត្រូវបានលើកយកមកនិយាយ។ ហោរារបស់ព្រះក៏មានជាប់ពាក់ព័ន្ធនៅក្នុងការថ្លែងប្រាប់អំពីអនាគតដែរ តែនេះមិនមែនជាតួនាទីរបស់ពួកគេនោះទេ។ នៅពេលដែលពួកគេថ្លែងប្រាប់ពីអនាគតនោះ គឺដោយព្រោះព្រះអង្គបានចាត់បញ្ជូនពួកគេ

ឱ្យមក ដើម្បីធ្វើការព្រមានអំពីបណ្តាសានៃសេចក្តីតាំងសញ្ញារបស់ទ្រង់ដល់ពួកបណ្តាជនអ៊ីស្រាអែល ចំពោះការមិនស្តាប់បង្គាប់របស់ពួកគេ និងប្រកាសអំពីសេចក្តីសន្យារបស់ទ្រង់។ ពួកហោរារបស់ព្រះជាម្ចាស់ថ្លែងទំនាយពីអនាគតមិនមែនគ្រាន់តែដើម្បីបំពេញបំណងចិត្តដែលចេះចង់ដឹងរបស់មនុស្ស ឬដើម្បីឱ្យពួកគេធ្វើការសំរេចចិត្តចំពោះថ្ងៃអនាគត ថាតើថ្ងៃណាជាថ្ងៃល្អដែលពួកគេត្រូវរៀបវិវាហមង្គលនោះទេ។ល។ តែតួនាទីពួកហោរារបស់ព្រះគឺជា អ្នកកំណែទំរង់ ដោយអំពាវនាវឱ្យរាស្ត្ររបស់ព្រះបានស្មោះត្រង់ចំពោះព្រះអង្គ (ហើយនោះមានន័យថា ស្មោះត្រង់ចំពោះសេចក្តីតាំងសញ្ញា ដែលទ្រង់មានជាមួយពួកគេ) ហើយឱ្យពួកគេចេះដាក់ទំនុកចិត្តលើព្រះអង្គ។

ហេតុផលមួយដែលព្រះជាម្ចាស់ស្អប់ចំពោះការទស្សន៍ទាយគឺ ដោយសារនៅពីក្រោយការទស្សន៍ទាយនោះ មនុស្សតែងគិតថា មានព្រះ ឬវិញ្ញាណ ឬទេវតាដ៏ទៃទៀត ដែលធំជាងព្រះដ៏ពិត ដែលបានបើកសម្តែងព្រះអង្គទ្រង់នៅក្នុងព្រះគម្ពីរ ហើយវិញ្ញាណទាំងនោះជាអ្នកគ្រប់គ្រងហេតុការណ៍គ្រប់យ៉ាង ដែលកើតឡើងក្នុងពិភពលោកនេះ។ ជំនឿបែបនេះនាំមនុស្សឱ្យដាក់ទំនុកចិត្តលើវិញ្ញាណទាំងអស់នោះ ហើយចេះតែបន្តធ្វើការនោះនៅក្នុងជីវិត។

នេះជាមូលហេតុមួយ តែនៅមានមូលហេតុច្រើនជាងនេះទៀត ដែលធ្វើឱ្យព្រះទ្រង់ស្អប់ចំពោះការប្រើរបៀបទស្សន៍ទាយនេះ។

លទ្ធផលចំពោះការអនុវត្តនូវរបៀបទស្សនទាយនេះធ្វើឱ្យមនុស្សឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ធ្លាក់ទៅក្នុងភាពខ្មៅងងឹតនិងការយល់ច្រឡំយ៉ាងធ្ងន់ធ្ងរ។

ប៉ុន្តែ សំរាប់រាស្ត្ររបស់ព្រះជាម្ចាស់វិញ មិនត្រូវមានការយល់ច្រឡំដូចនេះនោះទេ ដ្បិតអីពួកគេដឹងយ៉ាងច្បាស់ថា អតីតកាល បច្ចុប្បន្ន និងអនាគតរបស់ពួកគេនៅក្នុងកណ្តាប់ព្រះហស្តរបស់ទ្រង់ ដែលគង់នៅស្ថានសួគ៌ ទ្រង់បាន ប្រទានគ្រប់របស់ទាំងអស់ និងបានបើកសំដែងព្រះហឬទ័យរបស់ទ្រង់នៅក្នុងព្រះគម្ពីររួចរាល់ទៅហើយ។ កត្តាតែមួយគត់ដែលកំណត់ពីជោគវាសនាចុងក្រោយបង្អស់របស់មនុស្សនោះគឺថា ពួកគេនឹងត្រឡប់បែរមករកព្រះជាម្ចាស់ ដោយទទួលជឿ និងដើរតាមព្រះយេស៊ូវគ្រីស្ទ ឬបដិសេធន៍ព្រះអង្គ។

## គ្រីស្ទបរិស័ទ ការបើកសំដែង និងព្រះហឫទ័យរបស់ព្រះជាម្ចាស់

តើគ្រីស្ទបរិស័ទយើងត្រូវឆ្លើយតបយ៉ាងដូចម្តេចទៅចំពោះការទស្សន៍ទាយទាំងអស់នោះ? ប្រសិនបើយើងឆ្លើយថា យើងជាគ្រីស្ទបរិស័ទមិនត្រូវធ្វើការទេ នោះយើងត្រូវសួរខ្លួនឯងថា តើយើងគួរតែធ្វើអ្វីវិញ? តើយើងគួរតែស្វែងរកទីសំគាល់ និងការបើកសំដែងថ្មីផ្សេងៗពីព្រះដើម្បីឱ្យយើងអាចយល់ពីព្រះហឫទ័យរបស់ទ្រង់ឬ?

សំនួរពិភាក្សា

១. ចូរគិតថា មានគ្រីស្ទបរិស័ទម្នាក់ឈ្មោះ សំណាង។ គាត់ចង់ធ្វើជាស្ថាបត្យករផងនិងជាជាងជួសជុលរថយន្តផង។ គាត់មានការពិបាកក្នុងការសំរេចចិត្តថា គាត់គួរតែជ្រើសរើសយកមួយណា។ ក្នុងនាមជាគ្រីស្ទបរិស័ទមួយរូប គាត់ចង់ផ្គាប់ចិត្តព្រះជាម្ចាស់។ ដូច្នេះ គាត់បានប្រឹងប្រែងស្វែងរកទីសំគាល់ពីព្រះអម្ចាស់ ដើម្បីឱ្យដឹងថា តើអាជីពមួយណាដែលគាត់គួរតែចាប់យក។ គាត់ធ្វើការនេះដោយអធិស្ឋានតម ហើយចាំស្តាប់សំឡេងរបស់ព្រះអង្គប្រាប់មកគាត់អំពីអាជីពដែលគាត់ត្រូវចាប់យក។ សំនួរសួរថា តើអ្វីដែលគាត់កំពុងធ្វើនេះជារឿងត្រឹមត្រូវឬទេ?

២. ចូរគិតថា មានគ្រីស្ទបរិស័ទម្នាក់ទៀតឈ្មោះ វណ្ណា។ វណ្ណាបានបាក់ចិត្តស្រឡាញ់នារីម្នាក់។ ពេលនេះគាត់ចង់ដឹងថា តើគាត់គួរតែរៀបការជាមួយនារីម្នាក់នេះដែរឬទេ។ គាត់ចង់បានចំលើយថា បាន ឬមិនបានពីព្រះជាម្ចាស់។ គាត់ក៏បានដំណាលរឿងនេះប្រាប់ដល់មិត្តរបស់គាត់ម្នាក់ទៀត។ មិត្តភក្តិរបស់គាត់ម្នាក់នោះប្រាប់គាត់ថា យើងគួរតែអធិស្ឋានជាមួយគ្នា ហើយអ្នកត្រូវជំរះចិត្តគំនិតរបស់អ្នកចេញ អោយអស់ ហើយរងចាំមើលចំលើយពីព្រះជាម្ចាស់ បន្ទាប់ពីអធិស្ឋានតាមបំណងហឫទ័យរបស់ព្រះអង្គរួចហើយ។ សំនួរសួរថា តើវណ្ណានិងមិត្តរបស់គាត់ធ្វើដូចនេះត្រឹមត្រូវឬទេ?

៣. ធារ៉ាចង់ទិញឡានមួយ។ តែគាត់មិនប្រាកដក្នុងចិត្តថា តើគួរទិញឡានពណ៌ក្រហមឬពណ៌ស។ នៅទីបំផុត គាត់បានសម្រេចទិញយកឡានពណ៌ក្រហម។ ប៉ុន្តែបន្ទាប់ពីទិញបាន១សប្តាហ៍ក្រោយមក គាត់បានជួបគ្រោះថ្នាក់ចរាចរណ៍។ គាត់បានយកគ្រោះថ្នាក់នោះធ្វើជាទីសំគាល់ឬប្រផ្នូល ធ្វើជាការបើកសំដែងពីព្រះថា គាត់មិនគួរទិញឡានពណ៌ក្រហមនោះទេ តែគួរតែទិញយកពណ៌សវិញ។ គិតដូច្នេះហើយ គាត់ក៏យកឡានពណ៌ក្រហមរបស់គាត់នោះទៅដូរយកឡានពណ៌សវិញ។ សំណួរសួរថា តើគាត់ធ្វើដូចនេះត្រឹមត្រូវឬទេ?

ពាក់ព័ន្ធជាមួយរឿងទាំងអស់នេះ យើងត្រូវការគិតពិចារណានូវអ្វីដែលព្រះគម្ពីរបានចែងនិងបានបង្រៀន។

## ឧទាហរណ៍ ឬគំរូខ្លះៗដែលត្រូវបានលើកឡើងនៅក្នុងព្រះគម្ពីរ

នៅក្នុងគ្រាសញ្ញាចាស់មានឧទាហរណ៍ឬគំរូខ្លះៗដែលបង្ហាញថា ព្រះជាម្ចាស់បានប្រទានទំនាយដល់ រាស្ត្ររបស់ព្រះអង្គ គឺមានន័យថា ទ្រង់បានអនុញ្ញាតឱ្យរាស្ត្ររបស់ព្រះអង្គប្រើការទស្សន៍ទាយ ដែលព្រះអង្គបានប្រទានឱ្យ ជាក់ស្តែងដូចជាការទស្សន៍ទាយដោយប្រើយូរីមនិងធូមីម (និក្ខមនំ ២៨:៣០)។ ប៉ុន្តែនេះមិនមែនមានន័យថា ពួកគេមានសិទ្ធិអាចបង្កើតការទស្សន៍ទាយ ដោយប្រើឧបករណ៍ផ្សេងៗតាមអំពើចិត្តនោះឡើយ។ យើងមិនសូវដឹងច្បាស់ទេថាតើអ្វីជាយូរីម និងធូមីមនោះ ប៉ុន្តែគ្រាន់តែដឹងថា វត្ថុទាំងពីរនេះមិនបានរក្សាទុកសំរាប់រាស្ត្ររបស់ព្រះអង្គនៅក្នុងសញ្ញាថ្មីទេ។ ឧទាហរណ៍មួយទៀតគឺការទាយដោយធ្វើការចាប់ឆ្នោត។ នៅក្នុងព្រះគម្ពីរ ការចាប់ឆ្នោតត្រូវបានគេលើកយកមកនិយាយជាច្រើនដង (យ៉ូស្វេ ៧, ១៨:៦, ណាហ៊ុម ៣:១០, ១សាំយូអែល ១០, ១របាក្សត្រ ២៤)។ រីឯឧទាហរណ៍មួយដែលត្រូវបានលើកមកនិយាយនៅក្នុងព្រះគម្ពីរ យ៉ូណាស ១:៧ បានបង្ហាញប្រាប់យើងថា ទោះជាមានការទស្សន៍ទាយដោយការចាប់ឆ្នោត ដែលពួកសាសន៍ដទៃបានប្រើ ក៏ព្រះអង្គជាអ្នកគ្រប់គ្រងដែរ។ ប៉ុន្តែចូរចងចាំថា ទោះបីព្រឹត្តិការណ៍នេះមានសារៈសំខាន់ខ្លាំងចំពោះពួកនាវិកដើម្បីជួយសង្គ្រោះដល់អាយុជីវិតរបស់អ្នកធ្វើដំណើរក្នុងនាវានោះយ៉ាងណាក៏ដោយ ក៏អ្វីដែលសំខាន់សំរាប់ព្រះជាម្ចាស់នៅពេលនោះគឺដើម្បីសម្រេចគោលបំណងរបស់ទ្រង់នៅក្នុងជីវិតរបស់យ៉ូណាស ដើម្បីនាំគាត់ទៅកាន់ទីក្រុងនីនីវេ។ នៅក្នុងព្រះគម្ពីរកិច្ចការ ១:២៦ មានព្រឹត្តិការណ៍មួយបានកើតឡើងគឺ ការជ្រើសរើសលោក ម៉ាត់ធាស ដើម្បីជំនួសដំណែងរបស់យូដាស-អ៊ីស្ការីយ៉ុត។ គេធ្វើការជ្រើសរើសនេះដោយប្រើពិធីចាប់ឆ្នោត ហើយនេះគឺជាការចាប់ឆ្នោតចុងក្រោយបង្អស់ ដែលត្រូវបានលើកមកនិយាយនៅក្នុងព្រះគម្ពីរ។ ចំណែកលោកម៉ាត់ធាសវិញ ក៏ព្រះគម្ពីរមិនដែលលើកយកមក និយាយម្តងទៀតដែរ តែព្រះគម្ពីរបានពណ៌នាអំពីលោកប៉ុលវិញ ហើយលោកប៉ុលនេះឯងគឺជាអ្នក ជំនួសដំណែងរបស់យូដាស-អ៊ីស្ការីយ៉ុតពិតប្រាកដ។ សេចក្តីពិតនេះរួមជាមួយនឹងព្រឹត្តិការណ៍នៃការចាប់ឆ្នោតមិនត្រូវបានគេលើកយកមកនិយាយសារជាថ្មីម្តងទៀតនៅក្នុងសញ្ញាថ្មីឡើយ ហើយយើងក៏មិនបាច់ត្រូវការប្រើពិធីចាប់ឆ្នោតនេះមកអនុវត្តន៍នៅសម័យយើងនេះដែរ។

ព្រះជាម្ចាស់ទ្រង់ក៏បានមានបន្ទូលទៅកាន់រាស្ត្ររបស់ព្រះអង្គតាមរយៈសុបិន្តនិងទីសំគាល់ផ្សេងៗ ផងដែរ (ឧ. ដានីយ៉ែល ៧, ចៅហ្វាយ ៦:១៥-២២)។ ប៉ុន្តែត្រូវចងចាំថា អ្វីដែលព្រះអង្គបានធ្វើទៅចំពោះ រាស្ត្ររបស់ទ្រង់ ឧទាហរណ៍ដូចជាក្នុងករណីលោកអ័ប្រាហាំ កាលដែលលោកទទួលបង្គាប់ពីព្រះអង្គឱ្យធ្វើដំណើរចាកចេញពីស្រុកកំណើត លំនៅដ្ឋាន ឪពុកម្តាយ។ល។ ទ្រង់ធ្វើយ៉ាងនេះគឺដើម្បីបំពេញសំរេចផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះអង្គនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ដែលផែនការនេះបានបំពេញសំរេចនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ មានមនុស្សជាច្រើនបានយល់ច្រឡំចំពោះការនេះ ហើយបានអនុវត្តន៍ខុសផងដែរពេលដែលពួកគេអានអត្ថបទនេះ។ ពួកគេគិតថា ព្រះបង្គាប់លោកអ័ប្រាហាំឱ្យធ្វើការនេះ ដូច្នេះយើងក៏ត្រូវស្វែងរកហើយរងចាំស្តាប់ព្រះសូរសៀងរបស់ព្រះ មានបន្ទូលមកកាន់យើងដោយផ្ទាល់អំពីអ្វីដែលយើងត្រូវធ្វើផងដែរ។ ទីសំគាល់

ដែលគេតែងតែដកស្រង់យកមក និយាយញឹកញាប់បំផុតគឺនៅត្រង់គីឌានប្រើរោមចៀមធ្វើជាទីសំគាល់ (ចៅហ្វាយ ៦)។ លោកគីឌាន បានស្វែងរកទីសំគាល់អស្ចារ្យពីព្រះជាម្ចាស់។ នៅពេលក្រោយ យើងនឹងលើករឿងនេះមកនិយាយ បន្ថែមទៀត។

**<u>វិធីរបស់ព្រះជាម្ចាស់ និងគោលបំណងក្នុងការដឹកនាំ</u>**

ចូរអានព្រះគម្ពីរចោទិយកថា ១៨:១០-១៣ តើទង្វើបែបណាដែលជាទីស្អប់ខ្ពើមចំពោះព្រះអង្គ? ហើយហេតុអ្វី?

ចូរអានព្រះគម្ពីរចោទិយកថា ៣០:១១-១៦ នៅក្នុងបទគម្ពីរនេះ តើការអ្វីដែលព្រះទ្រង់ហាមមិនឱ្យរាស្ត្ររបស់ព្រះអង្គធ្វើ? ហើយហេតុអ្វី?

អ្វីដែលយើងនឹងមើលឃើញនោះគឺថា ព្រះជាម្ចាស់មិនដែលអនុញ្ញាតអោយមានការទស្សន៍ទាយតាមបែបបទណាមួយឡើយ ទោះជាពួកគ្រីស្ទបរិស័ទខ្លះស្វែងរកព្រះហឫទ័យរបស់ព្រះតាមរបៀបនេះក៏ ដោយ។ តាមពិត ពេលដែលពួកគេធ្វើការនេះ ពួកគេបានបរាជ័យក្នុងការដើរតាមព្រះហឫទ័យរួចទៅ ហើយ។ ប៉ុន្តែគ្រាន់តែថា ពួកគេមិនបានដឹងខ្លួនថា ពួកគេកំពុងតែធ្វើខុសនឹងព្រះហឫទ័យរបស់ព្រះនោះឡើយ។

នៅពេលដែលព្រះជាម្ចាស់ដឹកនាំរាស្ត្ររបស់ព្រះអង្គ គោលបំណងនៃការដឹកនាំនេះគឺដើម្បីនាំពួកគេឱ្យស្គាល់ទ្រង់ និងមានជីវិតគាប់ព្រះទ័យដល់ទ្រង់ នោះគឺទ្រង់នាំពួកគេឱ្យដើរតាមទ្រង់។ យើងត្រូវយល់ឱ្យបានច្បាស់ថា ព្រះជាម្ចាស់ទ្រង់ជាអ្នកដឹកនាំរាស្ត្ររបស់ព្រះអង្គ។ ព្រះអង្គមិនបានលាក់រឿងរ៉ាវផ្សេងៗទុកសំរាប់ចែកចាយជាមួយរាស្ត្ររបស់ព្រះអង្គ នៅពេលដែលពួកគេប្រារព្ធពិធីអ្វីមួយនោះទេ។ ទ្រង់បានប្រោសប្រទានការដឹកនាំដល់យើងយ៉ាងច្បាស់សំរាប់ជីវិតរស់នៅដែលគាប់ព្រះហឫទ័យរបស់ទ្រង់។ ប៉ុន្តែ យើងក៏ត្រូវតែស្វែងយល់ឱ្យបានច្បាស់ដែរពីរបៀប មធ្យោបាយ និងមូលហេតុដែលព្រះជាម្ចាស់ដឹកនាំរាស្ត្ររបស់ព្រះអង្គ។

ដំបូងព្រះជាម្ចាស់បានប្រោសប្រទានការដឹកនាំដល់យើងតាមរយៈព្រះគម្ពីរ។ ហេតុផលដែលព្រះគម្ពីរគឺជាទំរង់មួយនៃការដឹកនាំដំបូងនិងសំខាន់បំផុតគឺ ពីព្រោះព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះ ដែលពេញដោយអំណាច ហើយមិនលំអៀង (វត្ថុវិស័យ) ដូច្នេះព្រះគម្ពីរបើកសម្តែងព្រះហឫទ័យរបស់ព្រះ។ ដើម្បីឱ្យអាចទទួលបាននូវគុណប្រយោជន៍ពីការដឹកនាំរបស់ព្រះជាម្ចាស់តាមរយៈព្រះគម្ពីរ លុះត្រាតែយើងអានព្រះបន្ទូលរបស់ព្រះដោយយកចិត្តទុកដាក់ ឧស្សាហ៍ព្យាយាមនិងរៀនកាត់ស្រាយព្រះបន្ទូលរបស់ព្រះឱ្យបានត្រឹមត្រូវ។ តើអ្នកចង់ដឹងថា អ្វីជាបំណងព្រះហឫទ័យរបស់ព្រះសំរាប់ជីវិតរបស់អ្នកដែរឬទេ? បំណងព្រះហឫទ័យរបស់ព្រះសំរាប់ជីវិតយើងនោះគឺ *យើងត្រូវដឹកនាំជីវិតរបស់យើងដោយជឿជាក់ ទុកចិត្ត និងគោរព*

*ស្តាប់បង្គាប់ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយយើងអាចធ្វើការនេះបានដោយមានព្រះគម្ពីរជាអ្នកបង្រៀនយើង* (២ធីម៉ូថេ ៣:១៤-១៧)។ ចូរសរសេរចុះនូវអ្វីដែលព្រះគម្ពីរបានធ្វើតាមរយៈអត្ថបទព្រះគម្ពីរនេះ។

គ្រីស្ទបរិស័ទមិនត្រូវធ្វើការទស្សន៍ទាយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែត្រូវរស់នៅតាមព្រះទ័យព្រះអង្គវិញ ដោយស្គាល់ព្រះអង្គ និងព្រះហឫទ័យរបស់ទ្រង់ តាមរយៈព្រះបន្ទូលរបស់ព្រះអង្គដែរ គឺព្រះគម្ពីរ។ អត្ថបទព្រះគម្ពីរមួយទៀតដែលនិយាយពីព្រះទ័យរបស់ព្រះជាម្ចាស់សំរាប់ជីវិតរបស់យើងនោះគឺ ១ថែស្សាឡូនិច ៥:១៥-១៨។ អត្ថបទនេះសង្កត់ធ្ងន់ និងពន្យល់ថែមទៀតអំពី អ្វីដែលជាតម្រូវការក្នុងការជឿទុកចិត្តនិងស្តាប់បង្គាប់ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចូរចាំថា អ្វីដែលយើងបានពិភាក្សាទាក់ទងនិងបំណងព្រះទ័យរបស់ព្រះបង្ហាញថា វាគឺជាព្រះទ័យរបស់ព្រះជាម្ចាស់ដែលយើងត្រូវការភាពចាស់ទុំខាងជំនឿនៅក្នុងព្រះគ្រីស្ទ។ ចោទិយកថា ២៩:២៨ (អង់គ្លេស ចោទិយកថា ២៩:២៩) បានបង្រៀនយ៉ាងច្បាស់ថា អ្វីៗទាំងអស់ដែលបានបើកសំដែង គឺបានបើកសំដែងនៅក្នុងព្រះគម្ពីរ ហើយក្នុងគោលបំណង ដើម្បីឱ្យយើងរស់នៅក្នុងជីវិតមួយដែលជាទី គាប់ព្រះទ័យព្រះអង្គ។ ទន្ទឹមគ្នានោះ ក៏មានរឿងរ៉ាវជាច្រើនស្ថិតក្នុងភាពអាថ៌កំបាំងដែរ ហើយអ្វីៗ ដែលជាអាថ៌កំបាំងនោះ ក៏នៅតែរក្សាជាអាថ៌កំបាំងដដែល។ យើងមិនត្រូវព្យាយាមស្នើសូមឱ្យព្រះអង្គប្រទានការបើកសំដែងបន្ថែមទៀត ឬខិតខំស្វែងរកការបើកសម្តែងបន្ថែមទៀត ដើម្បីឱ្យស្គាល់ពីព្រះហឫទ័យរបស់ព្រះអង្គឡើយ។ យើងមិនត្រូវព្យាយាមគាស់កកាយអាថ៌កំបាំងដែលបានលាក់ទុកនោះ ដោយប្រើមន្តអាគមនោះឡើយ តែត្រូវដឹងប្រាកដច្បាស់ថា គ្រប់យ៉ាងដែលយើងត្រូវការ ព្រះជាម្ចាស់បានប្រោសប្រទានការបើកសំដែងមកឱ្យយើងរួចជាស្រេចហើយ។ នេះគឺជាចំនុចសំខាន់នៅក្នុងព្រះគម្ពីរចោទិយកថា ៣០:១១-១៦។ ព្រះដែលយើងកំពុងបំរើជា ព្រះដ៏ពិតដែលមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ជាព្រះនៃនគរស្ថានសួគ៌ ទ្រង់មិនមែនជាព្រះលាក់កំបាំងដែលបានលាក់ទុកនូវរឿងរ៉ាវគ្រប់យ៉ាងដែលយើងត្រូវការដឹងដើម្បីឱ្យយើងព្យាយាមស្វែងរកនៅកន្លែងណាមួយតាមរយៈ របៀបអាគមនៃការទស្សន៍ទាយរបស់យើងដូចជាព្រះ របស់នោះឡើយ។ អ្វីៗដែលជាការលាក់កំបាំងគឺសុទ្ធតែជាអ្វីដែលយើងមិនចាំបាច់ត្រូវការដឹងសោះ។ គ្រប់យ៉ាងដែលយើងពិតជាត្រូវការដឹង ត្រូវការស្គាល់នោះ ព្រះដែលប្រកបដោយអធិបតេយ្យភាពបានបើកសំដែងមកដល់យើងរួចហើយ។ ទ្រង់បានបើកសំដែងការទាំងនោះមកយើងរួចហើយនៅក្នុងព្រះគម្ពីរដែលជាការបើកសំដែងប្រកបដោយអំណាចហើយមិនលំអៀង (វត្ថុវិស័យ)។

នេះគឺជាចំនុចខុសគ្នាដ៏សំខាន់រវាងគ្រីស្ទបរិស័ទនិងសាសនាដទៃទៀត។ គ្មានអ្វីដែលលាក់កំបាំងនោះទេនៅក្នុងគ្រីស្ទបរិស័ទ។ គ្មានចំណេះដឹង អាថ៌កំបាំងពិសេសណាមួយដែល មានតែមនុស្សតិចតួចតែប៉ុណ្ណោះ ដែលអាចរកឃើញដោយការភាវនានោះឡើយ។ នេះហើយគឺជាហេតុផលដែលសាវកប៉ុលបានបដិសេធន៍ដាច់អហង្ការចំពោះទស្សនៈបែបនេះ ហើយលោកបានធ្វើការជំនុំជំរះផងដែរចំពោះអ្នកដឹកនាំ ឬគ្រូបង្រៀនខ្លះៗដែលបានធ្វើឱ្យភាពជាគ្រីស្ទបរិស័ទទៅប្រឡូកប្រឡាក់ជាមួយសាសនាអាថ៌កំបាំង ដូចដែលបានរៀបរាប់ខាងលើនេះ (ចូរអាន ២កូរិនថូស ៤:១-៣)។

យើងគួរតែប្រើគ្រប់ទាំងគំនិតប្រាជ្ញារបស់យើង ដើម្បីអានព្រះគម្ពីរដោយចិត្តឧស្សាហ៍ព្យាយាម ហើយប្រឹងប្រែងឱ្យអស់ពីកំលាំងកាយចិត្តដែលយើងមាន និងដែលព្រះអង្គបានប្រទានមកឱ្យយើង ដើម្បីចងចាំ សញ្ជឹងគិត និងឈ្វេងយល់ពីព្រះបន្ទូលរបស់ព្រះអង្គ។ នៅពេលដែលយើងធ្វើការនេះ យើងនឹងបានរឹងមាំក្នុងការស្គាល់ពីព្រះទ័យរបស់ព្រះ ហើយអាចដើរតាមព្រះហឫទ័យរបស់ទ្រង់បានកាន់តែប្រសើរឡើងថែមទៀតផង (ទំនុកដំកើង ១:១-៣, ១១៩:២៧, ៩៧)។

ទី២ យើងត្រូវអធិស្ឋាននៅពេលយើងអានព្រះគម្ពីរ។ ការអធិស្ឋានរបស់យើងជួយយើងឱ្យយល់ពី ព្រះបន្ទូលនិងព្រះហឫទ័យរបស់ទ្រង់។ ចូរអាននៅព្រះគម្ពីរកូលូស ១:៩-១៤។ យើងអធិស្ឋាននៅពេលដែលយើងអានព្រះគម្ពីរ មិនមែនដើម្បីឱ្យយើងអាចទទួលបាននូវព្រះបន្ទូលលាក់កំបាំងណាមួយ ដែលមិនមាននៅក្នុងអត្ថបទព្រះគម្ពីរនោះទេ តែយើងធ្វើការនេះគឺដើម្បីឱ្យយើងអាចរៀនអនុវត្តន៍ព្រះបន្ទូលនៅក្នុងចិត្តរបស់យើងវិញ។ យើងមិនគ្រាន់តែមានចំណេះដឹងត្រឹមខួរក្បាលដែលមិនអាចផ្លាស់ប្តូរជីវិតរបស់យើងបាននោះទេ ប៉ុន្តែចិត្តគំនិតរបស់យើងត្រូវមានការផ្លាស់ប្តូរនិងស្អាងជាថ្មីឡើងវិញដែរ ដើម្បីឱ្យយើងអាចទុកចិត្ត ជឿជាក់ ស្តាប់បង្គាប់ និងដើរតាមព្រះគ្រីស្ទ ដែលជាម្ចាស់ដោយក្តីស្រឡាញ់។ ការ ដែលដឹងថាព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនគ្រាន់តែជាគោលលទ្ធិប៉ុណ្ណោះទេ តែយើង អាចនឹងដឹងយ៉ាងច្បាស់ថា ព្រះជាម្ចាស់មានបន្ទូលមកកាន់យើងតាមរយៈព្រះគម្ពីរ។ ពេលដែលខ្ញុំក្លាយជា គ្រីស្ទបរិស័ទដំបូង ខ្ញុំមិនចាប់អារម្មណ៍ចំពោះការឮសំឡេងផ្ទាល់ពីព្រះជាម្ចាស់នោះទេ ព្រោះអី ខ្ញុំបានដឹងច្បាស់ហើយថា ព្រះជាម្ចាស់មានបន្ទូលមកខ្ញុំតាមរយៈព្រះគម្ពីររួចហើយ។ ព្រះបន្ទូលរបស់ទ្រង់តាម រយៈអត្ថបទព្រះគម្ពីរមានលក្ខណៈអស្ចារ្យណាស់ទៅហើយ ហើយប្រសិនបើខ្ញុំបានឮព្រះសូរសៀងពីព្រះអង្គផ្ទាល់ក៏មិនមានអ្វីដែលអស្ចារ្យជាងនោះដែរ។

ទី៣ យើងមិនត្រូវរៀនតែព្រះគម្ពីរប៉ុណ្ណោះទេ តែយើងត្រូវគោរពព្រះបន្ទូលដោយបន្ទាបខ្លួនផងដែរ។ នេះគឺជាការដែលសំខាន់ហើយក៏មានចែងយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរយ៉ាកុប។

ទី៤ យើងគួរតែស្វែងរកការដឹកនាំពីគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ និងប្រកបដោយប្រាជ្ញាវាងវៃ។

នេះគឺជារបៀបដែលព្រះជាម្ចាស់ប្រទានការដឹកនាំដល់រាស្ត្ររបស់ព្រះអង្គ។ យើងអាចមើលឃើញថា នេះគឺជាចំនុចខុសគ្នាស្រឡះជាមួយនឹងការដឹកនាំដោយប្រើរបៀនអាគម ទាយទំនាយ ឬប្រផ្នូលឬមន្តអាគម។ លើសពីនេះទៅទៀត នៅពេលដែលយើងមើលឃើញពីរបៀបដែលព្រះជាម្ចាស់ប្រើដើម្បីដឹកនាំ រាស្ត្ររបស់ព្រះអង្គនោះ យើងក៏អាចមើលឃើញថា ការដែលស្វែងរកការដឹកនាំតាមរយៈការទាយទំនាយ នោះគឺជាទង្វើមួយដែលពោពេញដោយអំពើបាប។

ការទាយទំនាយរបស់សាសន៍ដទៃ វាមិនគ្រាន់តែជាការដើរតាមព្រះនិងវិញ្ញាណក្លែងក្លាយផ្សេងៗនោះទេ លើសពីនេះទៅទៀត គ្រប់ទាំងវិធីនៃការទាយទំនាយ ទោះជាធ្វើឡើងដោយរបៀបណាក៏ដោយ ក៏ទង្វើទាំងអស់នោះនៅតែជាកាយវិការបែប

ខ្ជិលច្រអូសដដែល។ ការដែលស្វែងរកការដឹកនាំដោយប្រើការទាយទំនាយនោះគឺជាទង្វើមួយ ដែលមានភាពស្រួលជាងការដើរតាមផ្លូវ ឬវិធីរបស់ព្រះអង្គ ដូចដែលបានពណ៌នាពីខាងលើ ហើយវាក៏ជាទង្វើមួយដែលពោពេញដោយភាពខ្ជិលច្រអូសផងដែរ។ ផ្លូវរបស់ព្រះជាម្ចាស់ត្រូវការចំណាយពេលច្រើន ហើយត្រូវការថាមពលនិងភាពចាស់ទុំ។ វាទាមទារឱ្យមានការសិក្សាព្រះបន្ទូលរបស់ព្រះអង្គពេញមួយជីវិត មានការចំណាយពេលស្តាប់ការបង្រៀនល្អៗ និងការស្វែងរកជំនួយពីគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំជាដើម។ ការដែលស្វែងរកការដឹកនាំដោយប្រើការទាយទំនាយគឺជាទង្វើមួយបង្ហាញពីភាពក្មេងខ្ចីខាងជំនឿ ពីព្រោះការធ្វើបែបនេះមិនគ្រាន់តែបង្ហាញអំពីភាពខ្ជិលច្រអូសម្យ៉ាងប៉ុណ្ណោះទេ តែវាបានបង្ហាញអំពីភាពខ្វះឆន្ទៈក្នុងការទទួលខុសត្រូវចំពោះការសំរេចចិត្តផ្ទាល់ខ្លួនផងដែរ។ នេះគឺជាបញ្ហាមួយដែលអាចកើតឡើងដូចជាការសុំទីសំគាល់ពីព្រះជាម្ចាស់ដើម្បីឱ្យដឹងថា តើអ្នកណាដែលយើងត្រូវការរៀបការជាមួយ ឬតើអ្នកណាដែលកូនរបស់យើងគួររៀបការជាមួយជាដើម។ ការធ្វើបែបនេះអាចជាទង្វើមួយខ្វះ ឬមិនមានភាពចាស់ទុំក្នុងការទទួលខុសត្រូវ និងអាចទទួលរ៉ាប់រងចំពោះការសម្រេចចិត្តរបស់យើងផ្ទាល់។ ឧទាហរណ៍ថា ប្រសិនបើមានគ្រីស្ទបរិស័ទម្នាក់ជឿថា ព្រះបានបើកសំដែងឱ្យគាត់ដឹងថា គាត់ត្រូវរៀបការជាមួយនឹងស្ត្រីម្នាក់នេះ ឬបំរើទ្រង់នៅកន្លែងនេះមួយ ស្រាប់តែក្រោយមក ជីវិតអាពាហ៍ពិពាហ៍ ឬកិច្ចការបំរើព្រះរបស់គាត់ជួបប្រទះនូវភាពរកាំរកូស ពេលនោះប្រហែលជា គាត់អាចបន្ទោសដល់ព្រះអង្គចំពោះរឿងរ៉ាវអាក្រក់ផ្សេងៗ ដែលបានកើតមាននៅក្នុងជីវិតរបស់គាត់។ ប្រតិកម្មបែបនេះគឺជាសកម្មភាពមួយដែលគ្មានភាពចាស់ទុំទាល់តែសោះ ហើយគាត់ក៏ក្លាយជាមនុស្សដែលគ្មានការទទួលខុសត្រូវ និងមិនអាចទទួលខុសត្រូវចំពោះកិច្ចការនិងការសំរេចចិត្តរបស់ខ្លួនឯងផង។

អ្វីដែលយើងបាននិយាយខាងលើមិនមែនមានន័យថា យើងមិនគួរអធិស្ឋាន ដើម្បីសូមការដឹកនាំពីព្រះជាម្ចាស់សំរាប់ជីវិតរបស់យើង និងពួកជំនុំក្នុងការសំរេចចិត្តធ្វើអ្វីមួយប្រកបដោយភាពវៃឆ្លាតនោះទេ។ ប៉ុន្តែគ្រាន់តែថា នៅពេលដែលយើងអធិស្ឋានសូមការដឹកនាំពីទ្រង់ យើងមិនគួរស្វែងរកការបើកសំដែងឬទីសំគាល់អ្វីមួយ ដែលនឹងនាំឱ្យយើងរួចផុតពីទំនួលខុសត្រូវ ដូចដែលបានរៀបរាប់ខាងលើទេ។

ចូរអានព្រះគម្ពីរ ១ធីម៉ូថេ ៣:១-១៣។ តាមរយៈអត្ថបទព្រះគម្ពីរនេះ តើព្រះជាម្ចាស់ដឹកនាំយើងដោយរបៀបណាក្នុងការសំរេចចិត្តធ្វើការជ្រើសរើសអ្នកដឹកនាំពួកជំនុំណាមួយ?

***ចូរអានព្រះគម្ពីរទីតុស ១:៥-៩។ តាមរយៈអត្ថបទព្រះគម្ពីរនេះផងដែរ តើព្រះជាម្ចាស់ដឹកនាំយើងយ៉ាងដូចម្តេចដែរក្នុងការសំរេចចិត្តជ្រើសរើសអ្នកដឹកនាំក្នុងពួកជំនុំ?***

នៅពេលដែលលោកប៉ុលបង្រៀនដល់ធីម៉ូថេនិងទីតុសអំពីការតែងតាំងពួកចាស់ទុំនិងអ្នកជំនួយ លោកមិនដែលបង្រៀនពួកគេឱ្យតែងតាំងមនុស្សតាមរយៈទីសំគាល់អធិធម្មជាតិ ការបើកសំដែងថ្មី ឬការត្រាស់ហៅអធិធម្មជាតិនោះទេ។ ប៉ុន្តែផ្ទុយ

ទៅវិញ លោកបង្រៀនពួកគេឱ្យជ្រើសរើសមនុស្សដែលនៅក្នុងក្រុមជំនុំរបស់ពួកគេ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមានអំណោយទានសមស្រប សំរាប់ដឹកនាំ។ ឧបមាថា មានមនុស្សម្នាក់បាននិយាយថា ព្រះបានប្រទានការបើកសំដែងឱ្យគាត់បានក្លាយជាគ្រូគង្វាល ប៉ុន្តែស្រាប់តែពួកក្រុមជំនុំបានមើលឃើញថា គាត់មិនមានលក្ខណសម្បត្តិ និងអំណោយទានសមស្របល្មមសំរាប់ធ្វើការនោះទេ ដូច្នេះ អ្វីដែលគាត់បាននិយាយថា គាត់បានទទួលពីព្រះជាម្ចាស់មកនោះ ត្រូវចាត់ទុកជារឿងអសារបង់ និងត្រូវគេបដិសេធន៍ចោល។

នេះគឺជារឿងពិតរបស់ស្ត្រីម្នាក់។ ស្ត្រីម្នាក់នេះមិនក្រោកពីដំណេកទេ បើកាលណាគាត់គិតថា ព្រះវិញ្ញាណមិនទាន់ប្រាប់គាត់ឲ្យក្រោក។ នេះមានន័យថា គាត់នឹងក្រោកពីដំណេកនៅពេលគាត់គិតថា ព្រះវិញ្ញាណបានប្រាប់គាត់ឲ្យក្រោកឡើង។ ពេលក្រោកពីដំណេកហើយ គាត់មិនបើកទ្វារទេ លុះត្រាណាគាត់គិតថា ព្រះវិញ្ញាណបានមានបន្ទូលប្រាប់គាត់ឲ្យបើក ទើបគាត់បើក និងមានរឿងរ៉ាវផ្សេងៗជាច្រើនទៀត។ សកម្មភាពបែបនេះមិនមែនត្រឹមតែយល់ខុសអំពីការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះទេ តែនេះគឺជាការយល់ខុសអំពីព្រះជាម្ចាស់ និងរបៀបដែលទ្រង់ប្រាស្រ័យទាក់ទងជាមួយនិងរាស្ត្ររបស់ព្រះអង្គថែមទៀតផង។

ឥឡូវសូមគិតអំពីថៅកែម្នាក់និងអ្នកបំរើម្នាក់។ អ្នកបំរើម្នាក់នេះមានតួនាទីបោសសំអាតផ្ទះ។ ថៅកែរបស់គាត់បានណែនាំពីកន្លែងដែលត្រូវសំអាត។ល។ ថៅកែម្នាក់នេះនឹងមិនគិតថា អ្នកបំរើនឹងសួរគាត់គ្រប់យ៉ាងនោះទេ ដូចជាតើត្រូវសំអាតយ៉ាងម៉េច? ត្រូវសំអាតកន្លែងណាមុន ឬប្រើអ្វីសំរាប់សំអាត? តាមពិតទៅ អ្នកបំរើនោះមានគំនិត និងមានប្រាជ្ញាក្នុងការសំរេចចិត្តធ្វើកិច្ចការនោះ។ ថៅកែនឹងមានចិត្តរីករាយជាពន់ពេកណាស់ ពេលណាដែលអ្នកបំរើរបស់គាត់បានបំពេញកិច្ចការ ដែលគាត់បានដាក់ឲ្យធ្វើ។ ប្រសិនបើសូម្បីតែកិច្ចការយ៉ាងតូចបំផុតក៏ថៅកែនោះមិនឲ្យអ្នកបំរើសំរេចចិត្តដោយខ្លួនឯង នោះមានន័យថា ថៅកែនោះជាមនុស្សផ្តាច់ការ ហើយទំនាក់ទំនងរវាងគាត់និងអ្នកបំរើក៏ជាទំនាក់ទំនងបែបផ្តាច់ការដែរ។

ប៉ុន្តែ ចំពោះព្រះអម្ចាស់របស់យើងវិញ ទ្រង់មិនមែនផ្តាច់ការទេ ហើយទំនាក់ទំនងរបស់ព្រះអង្គជាមួយនិងរាស្ត្ររបស់ទ្រង់មិនមែនជាទំនាក់ទំនងបែបផ្តាច់ការនោះដែរ។ យើងមានគំនិតប្រាជ្ញាដែលព្រះអង្គបានប្រទានឲ្យយើង ហើយយើងត្រូវប្រើប្រាស់វា។ យើងមានសេរីភាពក្នុងការសំរេចចិត្តដោយខ្លួនឯង។ គ្រាន់តែថា ការសំរេចចិត្តរបស់យើងក្នុងជីវិត យើងព្យាយាមផ្គាប់ព្រះហឫទ័យរបស់ព្រះអង្គ និងរស់នៅជាបាវបំរើស្មោះត្រង់របស់ទ្រង់។ ប៉ុន្តែត្រូវចាំថា ការសំរេចចិត្តនេះនៅតែជារបស់យើង។ ជាការពិត ព្រះអង្គជាអ្នកគ្រប់គ្រងលើគ្រប់ទាំងអស់ តែនេះមិនមែនមានន័យថា ការទទួលខុសត្រូវរបស់យើងក្នុងការសំរេចចិត្តក៏ទ្រង់ដកយក ដោយទ្រង់ធ្វើការសំរេចចិត្តជំនួសយើងនោះទេ។ មានរឿងមួយទៀតដែលទាក់ទងនិងរឿងនេះដែរគឺរឿង ឪពុកនិងកូនស្រី។

ឪពុកមានកូនស្រីម្នាក់។ ឪពុកម្នាក់នេះបានធ្វើការសំរេចចិត្តគ្រប់ទាំងអស់សំរាប់កូនស្រី ដូចជា តើត្រូវសិក្សាអ្វី តើការងារអ្វីដែលគួរធ្វើ តើនាងគួររៀបការជាមួយអ្នកណា ត្រូវញុំាអ្វី ពេលណានាងត្រូវងើបពីគេង ហើយរៀងរាល់ថ្ងៃនាងគួរតែទៅកន្លែងណាខ្លះ។ ល។ ទំនាក់ទំនងបែបនេះគឺជាទំនាក់ទំនងបែប ផ្តាច់ការ ហើយក៏គ្មានប្រយោជន៏អ្វីដែរ។ ការធ្វើយ៉ាងនេះនឹងនាំឲ្យកូនស្រីរបស់ខ្លួនគ្មានការរីកចំរើន ពេញវ័យក្នុងការទទួលខុសត្រូវចំពោះការប្រើប្រាស់ប្រាជ្ញារបស់នាង។ ហើយនោះនឹងក្លាយជាការចិញ្ចឹមបីបាច់ដ៏អាក្រក់ផងដែរ។ ការនេះធ្វើឲ្យនាងជិតជាប់ក្នុងភាពភ័យខ្លាច ហើយនាងតែងមានការភ័យខ្លាចក្នុងការធ្វើការសំរេចចិត្ត ព្រោះខ្លាចធ្វើទៅមិនត្រូវចិត្តឪពុក។

ឥឡូវនេះសូមគិតមើលពីស្ថានភាពដែលអាក្រក់ជាងនេះទៅទៀត។ ឪពុកម្នាក់នេះមិនត្រឹមតែធ្វើការសំ រេចចិត្តលើគ្រប់ការទាំងអស់នោះទេ តែសូម្បីអ្វីជាការសំរេចចិត្តរបស់គាត់នោះ ក៏គាត់មិនប្រាប់ដល់នាងដែរ។ គាត់រក្សាការសំរេចចិត្តរបស់គាត់អំពីអ្វីដែលនាងត្រូវធ្វើទៅចំពោះគាត់ទុកជាអាថ៌កំបាំង។ ដើម្បីឲ្យដឹងថា នាងគួរធ្វើអ្វីឲ្យត្រូវចិត្តឪពុក នាងបានព្យាយាមធ្វើពិធីផ្សេងៗ។ ឪពុកបែបនេះជាឪពុកអាក្រក់បំ ផុត។

នេះគឺជាទង្វើរបស់មនុស្សនៅក្នុងវប្បធម៌ផ្សេងៗ ដែលពួកគេបានធ្វើជាមួយនឹងព្រះរបស់ពួកគេ។ ពួកគេគិតថា មិនគួរនឹងធ្វើការសំរេចចិត្តដោយខ្លួនឯងនោះទេ តែត្រូវស្វែងរកបំណងព្រះ ឬ វិញ្ញាណ ឬទេវតារបស់ពួកគេវិញ។ ប៉ុន្តែព្រះ ឬវិញ្ញាណ ឬទេវតាទាំងអស់នេះមិនបានបង្ហាញបំណងរបស់ខ្លួនឲ្យពួកគេបានឃើញសោះ ដូច្នេះពួកគេក៏នាំគ្នាប្រារព្វពិធីផ្សេងៗ ដើម្បីឲ្យដឹងថា អ្វីជាបំណងរបស់ព្រះទាំងនោះ។

គ្រីស្ទបរិស័ទជាច្រើនក៏បានធ្វើការនេះដែរ ប៉ុន្តែនេះផ្ទុយស្រឡះពីព្រះដ៏ពិតនៃស្ថានសួគ៌ ដែលទ្រង់បានបើកសំដែងព្រះហឫទ័យរបស់ទ្រង់តាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះគម្ពីរ។ គ្រីស្ទបរិស័ទត្រូវស្រឡាញ់ព្រះអង្គ ហើយត្រូវយល់ពីសេចក្តីស្រឡាញ់របស់ទ្រង់ដែលជាបិតានៅស្ថានសួគ៌មានចំពោះយើងជាកូនរបស់ទ្រង់។ យើងត្រូវធ្វើជាអ្នកបំរើស្មោះត្រង់ ហើយខំប្រឹងធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ប៉ុន្តែ នេះមិនមែនមានន័យថា យើងផ្ទេរការទទួលខុសត្រូវនៃការសំរេចចិត្តរបស់យើងទៅព្រះអង្គនោះទេ តែនេះជាអ្វីដែលយើងបានធ្វើ នៅពេលយើងសូមទីសំគាល់អ្វីមួយ។ ការធ្វើការទស្សន៍ទាយ ឬការសូមទីសំគាល់អ្វីមួយនោះមានន័យថា យើងកំពុងតែគិតស្មានថា ព្រះអង្គបានធ្វើការសំរេចចិត្តដោយមិនបានប្រាប់យើងឲ្យដឹង ដូច្នេះតួនាទីរបស់យើងគឺ ស្វែងរកឲ្យឃើញនូវអ្វីដែលជាការសំរេចចិត្តនោះ។ នេះផ្ទុយពីព្រះគម្ពីរទាំងស្រុង ហើយក៏ត្រាប់តាមទង្វើនិងជំនឿរបស់ពួកសាសន៍ដ៏ទៃ ដែលមិនស្គាល់ព្រះផងដែរ។ ព្រះជាម្ចាស់បានប្រទានការបើកសំដែងតាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺជាព្រះគម្ពីរ ដែលទ្រង់បានបើកសំដែងគ្រប់យ៉ាងទាំងអស់ ដែលយើងត្រូវការដើម្បីស្គាល់ព្រះអង្គ និងបំណងព្រះហឫទ័យរបស់ទ្រង់ ដើម្បីឲ្យយើងក្លាយជាបាវបំរើស្មោះត្រង់របស់ទ្រង់។ យើងត្រូវប្រើគំនិតប្រាជ្ញារបស់យើងនិង (គំនិតប្រាជ្ញា

របស់អ្នកដ៏ទៃ) ដើម្បីទទួលខុសត្រូវចំពោះការសំរេចចិត្តរបស់យើង ហើយការធ្វើការសំរេចចិត្តរបស់យើងក៏ត្រូវចុះចូលចំពោះបំណងព្រះហឫទ័យរបស់ទ្រង់ ដែលបានបើកសំដែងនៅក្នុងព្រះបន្ទូលទ្រង់រួចហើយផងដែរ។

ដូច្នេះជាថ្មីម្តងទៀត នេះគឺជាហេតុផលដែលពេលព្រះអង្គប្រទានដំបូន្មានតាមរយៈព្រះបន្ទូលរបស់ទ្រង់ (គឺព្រះគម្ពីរ) ដល់អ្នកណាដែលយើងត្រូវការរៀបការជាមួយ តើអ្នកណាគួរធ្វើជាគ្រូគង្វាលនៅព្រះវិហារយើង តើការងារអ្វីដែលយើងត្រូវធ្វើ។ល។ មិនមានកន្លែងណាមួយដែលទ្រង់មានបន្ទូលដល់រាស្ត្ររបស់ទ្រង់ថា ត្រូវស្វែងរកទីសំគាល់ជាមុនសិននោះទេ។

## *អត្ថបទព្រះគម្ពីរដែលគេដកយកមកប្រើក្នុងរបៀបខុសឆ្គង*

មានអត្ថបទព្រះគម្ពីរជាច្រើនត្រូវបានគេយកមកប្រើក្នុងរបៀបខុសឆ្គង ដើម្បីគាំទ្រគំនិតរបស់ខ្លួនក្នុងការស្វែងរកការបើកសំដែងថ្មីៗពីព្រះអង្គ ក្នុងគោលបំណងដើម្បីទទួលបានការដឹកនាំពីទ្រង់ ទាក់ទងនឹងការសំរេចចិត្តក្នុងដំណើរជីវិតផ្ទាល់ខ្លួន។ អត្ថបទព្រះគម្ពីរទាំងអស់នោះមានដូចជា៖

យេរេមា ២៩:១១ នៅក្នុងអត្ថបទនេះព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់ពួកអ៊ីស្រាអែលថា ព្រះអង្គមានផែនការណ៍សំរាប់ពួកគេ។ នៅពេលដែលគ្រីស្ទបរិស័ទយកអត្ថបទនេះមកអាន ពេលនោះ ពួកគេខ្លះចាប់ផ្តើមយកអត្ថបទនេះមកអនុវត្តក្នុងជីវិតរបស់ពួកគេផ្ទាល់ ដោយនិយាយថា ព្រះជាម្ចាស់បានមានផែនការណ៍សំរាប់ជីវិតរបស់ពួកគេ។ វាជាការពិតមែនហើយដែលថា ព្រះអង្គមានផែនការណ៍សំរាប់ជីវិតរបស់យើងនោះ ប៉ុន្តែគ្រាន់តែថា មានគ្រីស្ទបរិស័ទខ្លះបានប្រើទស្សនៈនេះក្នុងរបៀបមួយមិនត្រឹមត្រូវ ហើយក៏បានទាញជាសេចក្តីសន្និដ្ឋានក្នុងរបៀបមួយខុសឆ្គងដែរ។ មានអ្នកខ្លះគិតថា ដោយហេតុថា ព្រះអង្គមានផែនការណ៍សំរាប់ជីវិតយើង រួមមានទាំងអ្វីដែលយើងគួរធ្វើ អ្នកណាដែលយើងគួររៀបការជាមួយ ទីណាដែលយើងគួររស់នៅ អ្វីដែលយើងគួរទិញ។ល។ នោះពួកគេគិតថា យើងគួរតែស្វែងរកឱ្យឃើញថា អ្វីដែលជាផែនការណ៍របស់ព្រះអង្គនោះ។ នៅពេលដែលពួកគេមានគំនិតយ៉ាងនេះ នោះពួកគេប្រហែលជាចាប់ផ្តើមធ្វើកិច្ចការផ្សេងៗ ដើម្បីឱ្យទ្រង់ប្រទានការបើកសំដែងឱ្យពួកគេបានដឹងនូវអ្វីដែលជាព្រះហឫទ័យរបស់ព្រះអង្គសំរាប់ពួកគេ។ នៅពេលនោះ ពួកគេប្រហែលជាអាចចាប់ផ្តើមសង្កេតមើលទីសំគាល់ផ្សេងៗចេញពីព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើង។ ប៉ុន្តែនៅពេលដែលពួកគេធ្វើការទាំងនេះ ពួកគេកំពុងតែឃ្លាតចេញឆ្ងាយពីអ្វីដែលព្រះគម្ពីរយេរេមា ២៩ បាននិយាយហើយ។ នៅក្នុងអត្ថបទព្រះគម្ពីរនេះលោកយេរេមាកំពុងតែមានប្រសាសន៍ទៅកាន់រាស្ត្ររបស់ព្រះអង្គ ដែលកំពុងរស់នៅក្នុងគ្រានិរទេស ហើយពួកគេទាំងនេះមិនបានស្វែងរកផែនការណ៍របស់ព្រះអង្គ ដែលទ្រង់មានសំរាប់ពួកគេ ដោយសង្កេតមើលទីសំគាល់ ឬធ្វើពិធីសាសនា ដើម្បីឱ្យដឹងថា អ្វីជាផែនការណ៍របស់ព្រះអង្គសម្រាប់ជីវិតផ្ទាល់នោះទេ។ ការបើកសំដែងរបស់ព្រះអង្គប្រកបដោយអធិបតេយ្យភាព

ព្រះអង្គបានបើកសំដែងព្រះហឫទ័យរបស់ទ្រង់តាមរយៈពួកហោរារបស់ទ្រង់ ហើយយើងអាចមើលឃើញផែនការណ៍នេះនៅក្នុងព្រះគម្ពីរបាន។

ចៅហ្វាយ ៦ នេះគឺជាអត្ថបទព្រះគម្ពីរមួយ ដែលគ្រីស្ទបរិស័ទមួយចំនួនបានយកមកប្រើក្នុងរបៀបមួយខុសឆ្គងយ៉ាងខ្លាំងដែរ។ នៅក្នុងអត្ថបទនេះព្រះមានបំណងប្រើលោកគីឌានឱ្យទៅជួយសង្គ្រោះដល់ រាស្ត្ររបស់ព្រះអង្គពីពួកសត្រូវរបស់ពួកគេ។ ទ្រង់បានជ្រើសរើសលោកគីឌាន ហើយប្រាប់លោកថា ទ្រង់បានបញ្ជូនគាត់ឱ្យបំពេញតួនាទីនេះ។ ប៉ុន្តែយើងឃើញថាគីឌាន លោកខ្វះជំនឿលើព្រះអង្គ លោកក៏បានសុំទីសំគាល់ពីព្រះអង្គ ដោយដាក់រោមចៀមហាលទឹកសន្សើម។ មូលហេតុដែលធ្វើឱ្យ លោកសុំទីសំគាល់ពីព្រះជាម្ចាស់គឺ ដោយសារតែភាពខ្វះជំនឿរបស់លោក។ ដូច្នេះអត្ថបទនេះមិនបាន ប្រាប់យើង ឬលើកទឹកចិត្តយើងឱ្យយកលោកគីឌានធ្វើជាគំរូសំរាប់យើងអនុវត្តតាមនោះទេ។ អត្ថបទ នេះមិនបានបង្ហាញពីគំរូនៃជំនឿរបស់លោកគីឌាននោះទេ តែបង្ហាញពីភាពខ្វះជំនឿរបស់លោកវិញ។ យ៉ាងនេះហើយបានជាលោកទូលអង្វរដល់ព្រះអង្គកុំឱ្យទ្រង់មានសេចក្តីខ្ញាល់នឹងគាត់ (ខ៣៩)។ សេចក្តីបង្រៀនសំខាន់នៅក្នុងអត្ថបទនេះគឺភាពស្មោះត្រង់របស់ព្រះអង្គក្នុងការជួយសង្គ្រោះរាស្ត្ររបស់ព្រះអង្គ ទោះជាគីឌាន លោកខ្វះជំនឿទៅចំពោះព្រះអង្គក៏ដោយ។ នៅក្នុងព្រះគម្ពីរទាំងមូលមិនមានកន្លែងណាផ្សេងទៀត ដែលគេបានយកអត្ថបទនេះមកប្រើដើម្បីទុកជាគំរូសំរាប់ឱ្យពួកគ្រីស្ទបរិស័ទប្រតិបត្តិតាមឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅតែមានគ្រីស្ទបរិស័ទជាច្រើនបាន យកអត្ថបទនេះមកបង្រៀនថា លោកគីឌានគឺជាគំរូសំរាប់យើងប្រតិបត្តិតាម។ ពួកគេបានលើកយក «ការដាក់រោមចៀម» របស់លោកគីឌានមកនិយាយថា តាមរយៈគំរូនេះពួកគេអាចសុំទីសំគាល់ពីព្រះជាម្ចាស់ ដើម្បីជួយពួកគេក្នុងការធ្វើការសំ រេចចិត្ត ទាក់ទងនឹងជីវិតរស់នៅរបស់ពួកគេ។ ប៉ុន្តែសំរាប់យើង យើងត្រូវចងចាំថា សេចក្តីបង្រៀនចំបងនៅក្នុងអត្ថបទនេះគឺ ព្រះជាម្ចាស់ធ្វើការដើម្បីជួយសង្គ្រោះរាស្ត្ររបស់ព្រះអង្គ។ ទ្រង់មិនបានប្រោសប្រទានការដឹកនាំជាលក្ខណៈបុគ្គលដល់លោកគីឌាន ទាក់ទងនឹងជីវិតរបស់គាត់ផ្ទាល់នោះទេ។

ទំនុកដំកើង ៣២:៨ នៅពេលដែលគេមើលខនេះ គេគិតថា នៅក្នុងខនេះព្រះជាម្ចាស់បានមានបន្ទូលថា ទ្រង់នឹងមានបន្ទូលចំៗមកកាន់យើងតែម្តង ទាក់ទងនិងជំរើសផ្សេងៗក្នុងជីវិតយើង។ ប៉ុន្តែ តាមពិតនោះមិនមែនជាអ្វីដែលខគម្ពីរនេះបាននិយាយនោះទេ។ អ្វីដែលមាននៅក្នុងខគម្ពីរនេះគឺ ស្តេចដាវីឌបាននិយាយទៅកាន់ពួកអ៊ីស្រាអែល ទាក់ទងនឹងផ្លូវនៃជីវិតដែលពួកគេគួរដើរ (រស់នៅ) ហើយយើងអាចមើលឃើញសេចក្តីបង្រៀនរបស់លោកទាក់ទងនឹងបញ្ហានេះនៅក្នុងខ៩-១១។ ផ្លូវជីវិតដែលពួកអ៊ីស្រាអែលគួរប្រតិបត្តិនោះគឺ រក្សាការប្រតិបត្តិតាមផ្លូវរបស់ព្រះ ដែលទ្រង់បានបើកសំដែងរួចហើយនៅក្នុងព្រះគម្ពីរ។

សុភាសិត ៣៥-៦ នេះក៏ជាខគម្ពីរមួយដែលគេបានយកមកប្រើក្នុងផ្លូវខុសឆ្គងយ៉ាងខ្លាំងផងដែរ។ ពួកគេបានប្រើខគម្ពីរនេះយកមកគាំទ្រគំនិតមួយ ដែលលើកឡើងថា យើងមិនគួរប្រើគំនិតប្រាជ្ញារបស់យើងឡើយ ដែលតាមពិតខគម្ពីរនេះនិយាយ

យ៉ាងនេះវិញថា កុំឱ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។ នេះគឺជាការដកយកឃ្លានៃខគម្ពីរមកអនុវត្តក្នុងរបៀបមួយខុសឆ្គង។ នៅឃ្លាទី២នៃខគម្ពីរនេះដែលនិយាយថា ទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង គេបានកាត់ស្រាយឃ្លានេះយ៉ាងនេះថា ទ្រង់នឹងប្រទានការដឹកនាំដល់យើងម្នាក់ៗផ្ទាល់ ទាក់ទងនឹងការសំរេចចិត្តរបស់យើង។ គឺមានន័យថា ព្រះអង្គនឹងប្រទានដល់យើងនូវការបើកសំដែងថ្មីផ្សេងទៀត ដើម្បីតម្រង់ផ្លូវរបស់យើង។ ប៉ុន្តែ សំរាប់ពាក្យដែលគេប្រើនៅក្នុងភាសាហេព្រើរមានន័យយ៉ាងច្បាស់ថា យើងទទួលបានប្រាជ្ញា គឺជាប្រាជ្ញាមួយប្រភេទ ដែលមាននិយាយនៅក្នុងព្រះគម្ពីរសុភាសិតនេះតែម្តង។ វាគឺជាប្រាជ្ញាមួយប្រភេទដែលជួយយើងក្នុងការដឹកនាំដំណើរជីវិត ឱ្យបានជាទីគួរគាប់ចំពោះព្រះអង្គ ហើយការនេះនឹងកើតឡើងនៅពេលយើងជឿទុកចិត្តលើព្រះអង្គ។ វិធីសាស្រ្តចំបងដែលអាចធ្វើឱ្យយើងជឿជាក់លើព្រះអង្គជាជាងការពឹងអាងលើយោបល់ផ្ទាល់ខ្លួនបាននោះគឺ ដោយអានព្រះគម្ពីរ អានព្រះបន្ទូលព្រះ និងយល់ព្រមអនុញ្ញាតឱ្យព្រះបន្ទូលរបស់ព្រះអង្គផ្លាស់ប្តូរគំនិតរបស់យើង ដើម្បីឱ្យគំនិតរបស់យើងបានដើរតាមគំនិតរបស់ព្រះ។ ដូច្នេះ ខគម្ពីរនេះមិនបានបង្រៀនថា ក្រោយពេលយើងជឿទុកចិត្តលើព្រះអង្គហើយ ពេលនោះយើងនឹងទទួលបានការបើកសំដែងថ្មីពីព្រះអង្គ ដើម្បីដឹកនាំយើងក្នុងការសំរេចចិត្តធ្វើអ្វីមួយក្នុងឆាកជីវិតរបស់យើងនោះឡើយ។

ការដែលនិយាយថា ព្រះគម្ពីរបង្ហាញប្រាប់យើងពីព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះមិនមែនមានន័យថា យើងអាចប្រើព្រះគម្ពីរធ្វើជាក្បួនសំរាប់ការទាយទំនាយនោះទេ។ ពេលខ្លះពួកគ្រីស្ទបរិស័ទបានប្រើព្រះគម្ពីរក្នុងផ្លូវមួយមិនត្រឹមត្រូវដូចនេះដែរ។ ពួកគេប្រហែលជាប្រើព្រះគម្ពីរដូចជាសៀវភៅមន្តវិជ្ជា មួយក្បាល ដែលពួកគេអាចប្រើ ដើម្បីស្វែងរកការដឹកនាំពីព្រះជាម្ចាស់ ដោយគ្រាន់តែយកព្រះគម្ពីរមកបើកនៅចំពោះមុខ ហើយបន្ទាប់មកបិទភ្នែកចាក់ឱ្យចំខគម្ពីរណាមួយ រួចមកយកខគម្ពីរនោះមកកាត់ស្រាយស្វែងយល់ឱ្យដឹងថា តើខគម្ពីរនោះនិយាយពីអ្វីទៅចំពោះហេតុការណ៍ដែលកើតមាននៅចំពោះមុខ។ ឧទាហរណ៍ដូចជា មានគ្រីស្ទបរិស័ទម្នាក់មានចិត្តមន្ទិលសង្ស័យថា តើគាត់គួររៀបការជាមួយស្រ្តីម្នាក់នោះឬអត់។ គាត់ចង់បានចំលើយ បាទឬទេ ពីព្រះជាម្ចាស់។ ដោយមានការចង់ដឹងបែបនេះ គាត់ក៏ចាប់ផ្តើមយកព្រះគម្ពីរមកបើកដាក់នៅចំពោះមុខ ហើយបិទភ្នែកចាក់ឱ្យចំខគម្ពីរណាមួយ បន្ទាប់មកគាត់ចាប់ផ្តើមអានខគម្ពីរនោះ ហើយក៏រកឃើញថា មានពាក្យថា «ទេ» នៅក្នុងខគម្ពីរនោះ។ ឃើញដូចនេះ គាត់ក៏គិតថា នេះគឺជាទីសំគាល់ពីព្រះ នេះគឺជាការបើកសំដែងពីព្រះអង្គសំរាប់គាត់ ហើយគាត់ក៏សំរេចចិត្តថា មិនរៀបការជាមួយស្រ្តីម្នាក់នោះទេ។ ទង្វើបែបនេះមិនខុសអីពីរបៀបទាយទំនាយដោយប្រើផ្លែព្រួញរបស់សាសន៍ដទៃនោះទេ។ ប៉ុន្តែគ្រាន់តែថា ពួកគេធ្វើការផ្លាស់ប្តូរពីការប្រើឧបករណ៍ទស្សន៍ទាយរបស់សាសន៍ដទៃមកការប្រើឧបករណ៍របស់គ្រីស្ទបរិស័ទវិញតែប៉ុណ្ណោះ។ នេះបង្ហាញពីភាពបរាជ័យក្នុងការប្រែចិត្តចេញពីវិធីឬរបៀបក្នុងការស្វែងរកការដឹកនាំពីព្រះអង្គ ឬស្វែងរកព្រះហឫទ័យរបស់ទ្រង់។

វាគឺជារឿងមួយគ្រោះថ្នាក់ខ្លាំងណាស់ នៅពេលដែលគ្រីស្ទបរិស័ទណាម្នាក់រងចាំមើល «ទីសំគាល់» ឬការអស្ចារ្យដោយគ្រាន់តែដើរតាមគំរូឬពិធីពិសេសណាមួយ ដូចជាការតមអាហារ ឬអធិស្ឋានជាដើម នោះ។ ការដែលគាត់ធ្វើដូចនេះ វាមិនខុសអ្វីពីរបៀបទស្សន៍ទាយរបស់ពួកសាសន៍ដទៃនោះទេ ប៉ុន្តែ គ្រាន់តែថា គាត់ប្រើពាក្យឬបច្ចេកទេសតាមបែបគ្រីស្ទបរិស័ទ។ ពួកគ្រីស្ទបរិស័ទមិនគួរផ្លាស់ប្រែ ឬប្រែចិត្តចេញតែពីការស្វែងរកការដឹកនាំតាមរយៈរូបព្រះ ឬពីវិញ្ញាណផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះ ពួកគេគួរតែផ្លាស់ប្រែ ឬប្រែចិត្តចេញពីការស្វែងរកទីសំគាល់ពិសេសៗ ឬក៏ការបើកសំដែងថ្មីៗពីព្រះជាម្ចាស់ដើម្បីដឹកនាំពួកគេផងដែរ។ ការដែលបរាជ័យក្នុងការផ្លាស់ប្រែ ឬប្រែចិត្តចេញពីការនេះអាចនាំឱ្យមនុស្សជាច្រើនដែលរស់នៅក្នុងវប្បធម៌ផ្សេងៗ ដូចជាប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាជាដើម នឹងងាកបែរទៅថ្វាយបង្គំរូបព្រះវិញ។ ពួកគេប្រហែលជាចាប់ផ្តើមស្វែងរកទីសំគាល់ ឬការបើកសំដែងពីព្រះជាម្ចាស់ទុកជាមគ្គុទេសក៍។

ប៉ុន្តែនៅពេលដែលព្រះអង្គមិនឆ្លើយតប នោះពួកគេចាប់ផ្តើមខកចិត្ត និងតូចចិត្ត ហើយបន្ទាប់មកក៏វិលទៅថ្វាយបង្គំរូបព្រះ និងវិញ្ញាណផ្សេងៗវិញ ដើម្បីឱ្យទទួលបាននូវទីសំគាល់ ការបើកសំដែង និងការដឹកនាំសំរាប់ដំណើរជីវិតរបស់ពួកគេ។ អ្វីដែលជាបញ្ហាត្រង់នេះនោះគឺ ពួកគេមិនបានផ្លាស់ប្រែឬប្រែចិត្ត ពិតប្រាកដនៅឡើយទេ។ អ្វីដែលពួកគេគួរធ្វើនោះគឺ ពួកគេគួរតែផ្លាស់ប្រែចិត្តទាំងស្រុងចេញពីភាពក្មេងខ្ចី និងភាពមិនពេញវ័យនៃការចង់ចេះចង់ដឹងពីការបើកសំដែងថ្មីៗបន្ថែមទៀត ដើម្បីធ្វើជាមគ្គុទេសក៍សំរាប់ជីវិត។  លើសពីអ្វីដែលទ្រង់បានបើកសំដែងរួចហើយនោះ ហើយវិលបែរមកជ្រើសរើសយកភាពស្កប់ចិត្តចំពោះការបើកសំដែងដែលទ្រង់បានប្រោសប្រទានមកមនុស្សយើងរួចជាស្រេចហើយនោះវិញ ដែលព្រះអង្គបានបើកសម្តែងរួចជាស្រេចហើយនៅក្នុងព្រះគម្ពីរ។

តែចូរចងចាំថា នេះមិនមែនមានន័យថា ព្រះមិនអាចប្រទានទីសំគាល់ ឬការបើកសំដែងផ្សេងៗ ដើម្បីដឹកនាំប្រជារាស្រ្តរបស់ព្រះអង្គនោះឡើយ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ត្រូវចាំថា មាន២ចំនុចដែលយើងត្រូវចងចាំ។ ទី១ នៅពេលដែលព្រះអង្គធ្វើការនោះ វាគឺជាបទពិសោធន៍មួយដែលប្លែកខុសពីធម្មតា។ យើងមិនគួររំពឹងចង់បាននូវបទពិសោធន៍យ៉ាងនេះមកធ្វើជាបទដ្ឋានសំរាប់ជីវិតជាគ្រីស្ទបរិស័ទឡើយ ដ្បិតអីសូម្បីសាវកប៉ុល លោកក៏កម្រជួបផងដែរនូវបទពិសោធន៍អស្ចារ្យយ៉ាងនេះនោះ។ ទី២ មានពួកគ្រីស្ទបរិស័ទខ្លះគិតថា នៅពេលយើងចង់បានទីសំគាល់ ឬការបើកសំដែងពីព្រះអង្គ យើងត្រូវរៀបចំពិធីផ្សេងៗថ្វាយព្រះអង្គ។ ប៉ុន្តែសេចក្តីពិតបានប្រាប់យើងឱ្យដឹងថា មិនមានកន្លែងណាមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលបានបង្រៀនយើងយ៉ាងដូច្នោះទេ គឺមិនបានបង្រៀនយើងថា ព្រះជាម្ចាស់បានប្រទានទីសំគាល់ ឬការបើកសំដែងរបស់ទ្រង់ដល់គ្រីស្ទបរិស័ទនៅពេលដែលពួកគេប្រឹងប្រែងធ្វើពិធីផ្សេងៗដើម្បីផ្គាប់ចិត្តព្រះអង្គឡើយ។ បទពិសោធន៍នៅតាមផ្លូវទៅក្រុងដាម៉ាស់របស់លោកប៉ុលមិនមែនបានមកដោយលោកខំប្រឹងស្វែងរកនោះទេ។ ចំណែកឯនិមិត្តរបស់លោកពេត្រុសនៅក្នុងព្រះគម្ពីរ (កិច្ចការ ១០:៩-១៩) ដែលលោកទទួលបានពីព្រះអង្គមក ក៏មិនមែនជាលទ្ធផលនៃការខិតខំស្វែងរករបស់គាត់ ប្រយោជន៍

ដើម្បីស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះដែរ។ ការបើកសំដែងដ៏អស្ចារ្យលើសលប់ដែលលោកប៉ុលបានទទួលពីព្រះអង្គ (២កូរិនថូស ១២) ក៏មិនមែនជាលទ្ធផលនៃការខំប្រឹងប្រែងរបស់លោក ដើម្បីឱ្យបានបទពិសោធន៍នោះដែរ។ លើសពីនេះទៀត យើងឃើញថា ការបើកសំដែងនោះខុសប្លែកហួសពីធម្មតា វាមានលក្ខណៈលើសលប់ហួសល្បត់ ដែលធ្វើឱ្យលោកមិនចង់និយាយប្រាប់អ្នកផ្សេងទៀតឱ្យបានដឹងពីការនោះ។ ប៉ុលមិនបានគិតថា បទពិសោធន៍ទាំងនោះអស្ចារ្យណាស់ ហើយគាត់គួរតែលើកទឹកចិត្តដល់បងប្អូនគ្រីស្ទបរិស័ទដទៃទៀត ដែលជាមិត្តរបស់គាត់ឱ្យខំប្រឹងស្វែងរក ដើម្បីឱ្យអាចទទួលបានបទពិសោធន៍ដូចលោកដែរនោះឡើយ។

សង្ខេបឡើងវិញ មានហេតុផលច្រើនយ៉ាងដែលការទាយទំនាយនិងការប្រឹងប្រែងស្វែងរកទីសំគាល់ ផ្សេងៗគឺជាការខូចអាក្រក់នៅចំពោះព្រះអង្គ។ ហេតុផលទាំងនោះមាន៖

១. ការទាយទំនាយរបស់ពួកសាសន៍ដទៃ ដូចជាពួកតារាសាស្រ្តជាដើម ពួកគេគិតថា វត្ថុផ្សេងៗ ជាអ្នកគ្រប់គ្រងលើព្រឹត្តការណ៍ជាងព្រះដ៏ពិត។ នេះគឺជាការប៉ាន់ស្មានមួយខុសទាំងស្រុង។

២. ព្រះជាម្ចាស់មិនមែនជាព្រះដែលលាក់ទុករឿងរ៉ាវដែលទ្រង់ចង់ឱ្យយើងដឹង តែមិនបានបើកសំដែងឱ្យយើងឃើញនោះទេ លុះត្រាណាយើងរៀបចំពិធីណាមួយសិនមុននឹងទ្រង់បើកសំដែងការនោះឱ្យយើងឃើញ។ ព្រះអង្គមិនមានលក្ខណៈយ៉ាងនេះនោះទេ។ ផ្ទុយទៅវិញ ព្រះអង្គ បានបើកសំដែងគ្រប់ទាំងអ្វីៗ ដែលព្រះអង្គចង់បើកសំដែង និងចង់ឱ្យយើងដឹង គឺគ្រប់ទាំងអ្វីៗ ដែលយើងត្រូវការ ប្រយោជន៍ឱ្យយើងអាចទុកចិត្តនិងស្តាប់បង្គាប់ព្រះអង្គបាន។ ប៉ុន្តែអ្វីដែលព្រះអង្គមិនចង់ឱ្យយើងដឹង អ្វីដែលជាអាថ៌កំបាំងនោះ នៅតែរក្សាជាអាថ៌កំបាំងដដែល មិនមានការបើកសំដែងអ្វីថ្មីផ្សេងទៀតនោះទេ (ចោទិយកថា ២៩:២៨ [ព្រះគម្ពីរអង់គ្លេស ចោទិយកថា ២៩:២៩])។

៣. បែបបទនៃការប្រារព្ធពិធីខ្លះៗ ដូចជាការទុកចិត្តលើប្រផ្នូលជាដើម គឺជាទង្វើមួយដែលបង្ហាញពីភាពបរាជ័យក្នុងការយល់ថា ព្រះអង្គដឹកនាំរាស្រ្តរបស់ព្រះអង្គនិងបើកសំដែងពីព្រះទ័យរបស់ព្រះអង្គចំៗតែម្តង តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ មិនមែនតាមរយៈប្រផ្នូល ហើយក៏មិនមែនតាមរយៈការផ្គត់ផ្គង់របស់ព្រះអង្គដែរ។

៤. វាគឺជាទង្វើមួយដែលយកមនុស្សជាសំខាន់ ជាចំនុចកណ្តាល ទោះបីគេធ្វើ «ពិធីទាយទំនាយ» នោះតាមរបៀប «គ្រីស្ទបរិស័ទ»ក៏ដោយ។ បានសេចក្តីថា គេកាត់ស្រាយរឿងរ៉ាវដែលបានកើតឡើងតាមវិធីរបស់មនុស្សទាំងស្រុង ដោយយកមនុស្សយើង សុខុមាលភាពរបស់យើង អនាគតរបស់យើង ការចាប់ អារម្មណ៍របស់យើង ការសម្រេចចិត្តរបស់យើង... មកធ្វើជាចំនុចកណ្តាលនៃការកាត់ស្រាយ។ ហើយយើងក៏បានដឹងដែរថា ការប៉ាន់ស្មានបែបនោះគឺជាការខុសឆ្គងទាំងស្រុង ដ្បិតអីព្រះអង្គ

បានសំដែងពីគោលបំណងរបស់ព្រះអង្គ ហើយព្រះគ្រីស្ទគឺជាចំនុចស្នូលសំខាន់នៃបំណងព្រះទ័យរបស់ព្រះជាម្ចាស់ មិនមែនជាយើងនោះទេ។

៥. តាមរយៈការប្រារព្ធពិធីខ្លះៗ គេគិតថាគេនឹងអាចទទួលបាននូវ «ការបើកសំដែង» ពីព្រះអង្គ ដែលនេះគឺជាការខុសឆ្គងទាំងស្រុង ពីព្រោះគេគិតថា មនុស្សត្រូវធ្វើឬសំដែងនូវពិធីអ្វីមួយជាមុន ទើបវិញ្ញាណ ឬព្រះ ឬទេវតាណាមួយឆ្លើយតបតាមក្រោយ។ តាមពិតព្រះគម្ពីរបានបង្រៀនយើងផ្ទុយពីនេះវិញថា ព្រះជាម្ចាស់សំដែងព្រះបន្ទូលរបស់ទ្រង់ដល់មនុស្សជាមុន ទើបពួកមនុស្សទាំងនោះឆ្លើយតបតាមក្រោយ។

៦. វានាំមនុស្សឱ្យប្រឹងប្រែងរកការដឹកនាំនៅកន្លែងមិនត្រឹមត្រូវ ធ្វើឱ្យមនុស្សទាំងនោះលែងទុកចិត្តលើព្រះអង្គ ហើយនាំឲ្យមនុស្សសម្រេចចិត្តខុសក្នុងការធ្វើអ្វីមួយ។

៧. គេតែងគិតថា មានចំណេះដឹងអាថ៌កំបាំងពិសេស ដែលមនុស្សតែបន្តិចបន្តួចអាចទទួលបាន (គឺថាមនុស្សភាគច្រើនមិនដែលទទួលទេ)។ ការគិតស្មានបែបនេះគឺជាការខុសឆ្គង ហើយក៏ជារឿងសាមញ្ញមួយនៅក្នុងសាសនាខុសឆ្គងផងដែរ។

៨. នៅពេលដែលមានការសំរេចចិត្តក្នុងការធ្វើកិច្ចការអ្វីមួយ វាបាននាំមនុស្សឱ្យមានការខ្ជិលច្រអូសក្នុងការប្រើប្រាស់នូវគំនិតប្រាជ្ញារបស់ពួកគេ និងបង្កឱ្យពួកគេមិនចេះទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេថែមទៀតផង។

## សំនួរសារដើមនៃមេរៀន

១. តើការទស្សនទាយរបស់ពួកសាសន៍ដទៃមានអ្វីខ្លះ?

២. តើគេបានយកព្រះគម្ពីរយេរេមាជំពូកទី២៩ មកប្រើខុសឆ្គងដោយរបៀបណា?

៣. ចុះព្រះគម្ពីរចៅហ្វាយជំពូកទី៦វិញ តើគេបានយកមកប្រើខុសឆ្គងយ៉ាងដូចម្តេចដែរ?

៤. នៅក្នុងព្រះគម្ពីរទំនុកដំកើង ៣២:៨ ក៏គេបានយកមកប្រើក្នុងផ្លូវខុសឆ្គងដែរ។ តើខុសយ៉ាងដូចម្តេច?

៥. ហើយគេបានយកមកប្រើក្នុងរបៀបមួយខុសឆ្គងយ៉ាងដូចម្តេចដែរចំពោះព្រះគម្ពីរសុភាសិត ៣:៥-៦?

៦. ហេតុអ្វីបានជាការស្វែងរកការដឹកនាំតាមរយៈទីសំគាល់ផ្សេងៗគឺជាការខុស?

៧. តើអ្វីគឺជាគោលបំណងនៃការដឹកនាំរបស់ព្រះជាម្ចាស់?

៨. តើព្រះជាម្ចាស់ប្រោសប្រទានការដឹកនាំនេះដោយរបៀបណា?